# គ្រួសារពូសៅ



ជីជើង អទាតគជើង

# គ្រួសារពូសៅ

ដើមឡើយគ្រួសារពូសៅបានរស់នៅជាសមាជិក នៃសហគមន៍ ជនជាតិដើមភាគតិចមួយ ក្នុងចំនោមជនជាតិ ដើមភាគតិចផ្សេងទៀតនៅខេត្តរតនគិរី ។ ពួកគាត់ជាកសិករ ហើយ ពួកគាត់តែងប្រមូល អាហារ និងសំភារៈសំណង់ ទាំងឡាយ មកពីព្រៃឈើ ។



គ្រួសារពូសៅ បានឃើញអ្នកផ្សេងក្នុងភូមិកំពុងទិញម៉ូតូ និង ម៉ាញ៉េ ហើយក៏គិតថា នេះជាការ ល្អដែរសំរាប់ពួក គាត់។ ពួកគាត់បានគិតថា វាជាមធ្យោបាយមួយ ដែលធ្វើអោយពួក គាត់មិនមែនជាអ្នក ក្រីក្រ ហើយពួកគាត់នឹងបានក្លាយជាអ្នក ទាន់សម័យនឹងគេ។



គ្រួសារពូសៅក៏បានលក់ដីរបស់ពួកគេអោយទៅអ្នកចំនូលថ្មីមកពីខាងក្រៅដែលមានប្រាក់ ច្រើនហើយគេនិយាយថាៈ ការលក់ដីគឺជា មធ្យោបាយដ៏ប្រសើរបំផុតសំរាប់ គ្រួសារជនជាតិដើម ភាគតិចគួរតែធ្វើ។ គ្រាដំបូងគ្រួសារពូសៅសប្បាយរីករាយជាទីបំផុតដោយសារពួកគាត់មានម៉ូតូ និងម៉ាញ៉េ។



តែក្រោយមកម៉ូតូ និងម៉ាញ៉េរបស់គាត់ក៏ខូចអស់ហើយ គាត់ក៏គ្មានប្រាក់ ដើម្បីជួសជុល និងដីក៏គ្មាននៅសល់ ទៀតដែរ។

ម្ចាស់ដីថ្មីបាន ទទួលប្រាក់យ៉ាងច្រើន ពីការប្រើប្រាស់ដីនោះ។



ក្រោយមកពួកគាត់ក៏សំរេចចិត្តធ្វើជាកម្មករអោយម្ចាស់ដីថ្មី ការងារដែលពួកគាត់ធ្វើនោះ គឺជា អ្នកមើលកាត់ ស្មៅ និងថែរទាំដំណាំផ្សេង ៗ។

ម្ចាស់ដីថ្មីអាចជួលកម្មករបានជាច្រើន រីឯប្រាក់កំរៃដែល ពូសៅ ទទួលបានក៏មាន ចំនួនដ៏តិចតួចបំផុតដែរ។


100 m

ជាញឹកញាប់ គឺវាមិនគ្រប់គ្រាន់សំរាប់ការចាយវាយ ក្នុងគ្រួសារ
ពួកគេមិនដែលទទួលបាន អាហារល្អហើយឆ្ងាញ់សំរាប់បរិភោគ
ក្រោយមកក៏ធ្លាក់ ខ្លួន ឈឺ ។ នៅពេលដែល គ្រួសារ ពូសៅ មាន
ជំងឺ ពួកគេក៏ពុំមានប្រាក់សំរាប់ ទិញ ថ្នាំ ព្យាបាលដែរ ។
ហើយពួកគាត់ក៏ពុំមានប្រាក់សំរាប់អោយ កូនទៅរៀនផងដែរ ។
ចំនែកម្ចាស់ដីថ្មីក៏បានគិតថា ការ ប្រើម៉ាស៊ីនក្នុងកសិដ្ឋាន របស់
ពួកគេ ជំនួស កំលាំងពលកម្មមនុស្ស វាប្រសើរជាង ។



ក្រោយមក គ្រួសារពូសៅក៏សំរេចចិត្តទៅរស់នៅឯទីក្រុង ដើម្បីស្វែងរកការងារធ្វើនៅទីនោះ ។ ហេតុដោយពួកគាត់ ពុំមានប្រាក់ ពុំមាន កន្លែងស្នាក់នៅ ទើបពួកគាត់ត្រូវតែដេកនៅតាមចិញ្ចើមផ្លូវ ។ មនុស្សនៅទីក្រុងគេមិនពេញចិត្តការស្នាក់ នៅរបៀបនេះឡើយ ហើយនគបាលក៏បានដេញគ្រួសារពូសៅ អោយចាកចេញឆ្ងាយពីទីនោះទៀត ។ ប៉ុន្តែគ្រួសារពូសៅមិនដឹងថាត្រូវ ទៅទីណា ឡើយ ។ ធ្វើអោយគ្រួសារ-ពូសៅ ក្លាយជាអ្នកក្រតោកយ៉ាកជាទីបំផុត ពួកគាត់ គ្មានដីគ្មានប្រាក់ចំនួលគ្មានកំលាំងកំហែង ហើយពួកគេគ្មានអនាគត ។



ទីបញ្ចប់គ្រួសារ ពូសៅបានស្រម៉ៃឃើញដីរបស់គាត់ វប្បធម៌របស់ គាត់ និងសហគមន៍ របស់គាត់ គាត់បាននឹកដល់ ជីវិតរស់នៅរបស់សហគមន៍ ដែលត្រូវបានបែកបាក់ ដោយសារតែ ការលក់ដី។

ពួកគាត់បានបួងសួង សង្ឃឹមថា និងមិនមានការលក់ដីតទៅទៀតទេទៅថ្ងៃអនាគត។



**'*Our Land Our Future'* is a series of storybooks about land issues and indigenous peoples in Cambodia. The books are produced as both a literacy and awareness raising tool.**

**The Story in English - not a direct translation: The Sao Family**

**Page 1:** The Sao family lived as part of one of the many indigenous communities in Ratanakiri. They were farmers. They also gathered food and building materials from the forest.

**Page 3:** The Sao family saw other people buying motorbikes and cassette players and thought this would be a good thing for them. They thought it would mean they were not poor and that they had become part of the modern times.

**Page 5:** The Sao family sold their land to an outsider who had money and said that selling land was the best thing an indigenous family could do. At first the Sao family was very happy. They had a motorbike and a cassette player.

**Page 7:** But then…the Sao family's motorbike and cassette player broke and the Sao family had no money to fix them. They had no land either. The new landowner had been making money from the land.

**Page 9:** The Sao family then decided to work as laborers on the new landowner's land. They cut the grass and looked after the cash crops. The new owner had lots of people he could employ. The amount of money the Sao family got for working was very small.

**Page 11:** Many times it was not enough for the whole family. They did not have good food and they started to get sick. When the Sao family got sick they had no money for medical care. They also did not have money for their children's education. The new landowners thought it would be better to use machines for their farm work.

**Page 13:** The Sao family decided to move to the town to try to find work there. Because they had no money they had nowhere to stay. They had to sleep on the streets. The people in the town did not like this. The police told the Sao family to go away. But the Sao family did not have anywhere to go. The Sao family became very poor. They had no land. They had no income. They had no energy. They had no future. `

**Page 15:** The Sao family dreamt of their land, their culture and their community. They missed the community life. It was the life broken by selling land. They wished they had not sold their land. They wished they had not sold their future.

"This book are produced with financial support from the Danish Ministry of Foreign Affairs"

## រឿងនេះបង្កើតឡើងដោយគំរោង CFI សហការជាមួយអង្គការ ICC

### គណៈកម្មការត្រួតពិនិត្យ និងកែសំរួល

ក្រុមការងារថ្នាក់អក្ខរកម្មក្រៅប្រព័ន្ធផ្នែកភាសាគ្រឹង របស់អង្គការសហការ ខេត្តរតនគិរី

---

**គណៈកម្មការត្រួតពិនិត្យ**

លោក : គេង ខាំអយ

លោក : ប៉ាន់ គ្លីម

លោក : គួក កំប្រែង

អ្នកស្រី : ឡាំ ចានី

អ្នកស្រី : ក្លាយ ច្រម៉ច

ដីយើង អនាគតយើង គឺជាប្រភេទសៀវភៅរឿងមួយដែលនិយាយ អំពីបញ្ហាទំនាស់ដីធ្លី និងជនជាតិភាគតិចនៃប្រទេសកម្ពុជា ។ សៀវភៅនេះផលិតឡើងដើម្បីផលប្រយោជន៍ពីរគឺ មួយដើម្បី អោយជនជាតិចេះសរសេរផង និងសំរាប់ការអប់រំផង ។

**អ្នកនិពន្ធ**

លោក : ព្រហ្គម ព្រាន

អ្នករៀបរៀងរីបច្ចេកទេសកុំព្យូទ័រ

លោក : ម៉ុន សារឿន

លោក : យ៉េះ ប៉ាទូ

លោក : គឹម សាមៀន

**រចនារូបភាពដោយ**

លោក : បាំង កាន់ធឿម

---


សំរាប់ព័ត៌មានបន្ថែមអំពីអង្គការសហគមន៍ព្រៃឈើអន្តជាតិ សូមទាក់ទង:

អង្គការសហគមន៍ព្រៃឈើអន្តជាតិនៅកម្ពុជា

ផ្ទះលេខ ៨១ បេ ផ្លូវលេខ ៥៧ កែងផ្លូវលេខ ៣៩៨. សង្កាត់បឹងកេងកង១

ខ័ណ្ឌចំកាមន ក្រុងភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខ : (៨៥៥ ២៣) ២២០ ៧១៤

ទូរស័ព្ទសារលេខ : (៨៥៥ ២៣) ២២១ ៦៣៤

អ៊ីម៉ែល : cfioffice@cfi-cambodia.org.kh



This booklet project has been generously funded by the United States Agency for International Development, the John D. & Catherine T. MacArthur Foundation, and the International Work Group for Indigenous Affairs. The observations opinions expressed in this publication are those of the authors and do not necessarily reflect any opinion whatever of these donors.



**For further information about CFI, please contact:**

Community Forestry International
# 81b, Street 57, (Corner of St. 398), Sangkat Boeung Keng Kong 1, Khan Charmkar Morn, Phnom Penh, Cambodia
Tel: (855 23) 220 714
Fax: (855 23) 221 634
Email: cfioffice@cfi -cambodia.org.kh



ឧបត្ថម្ភការបោះពុម្ពដោយ

International Cooperation Cambodia

*International Work Group for Indigenous Affairs*